# សេរីភាពខាងការជួបប្រជុំ – ខែមករា ដល់ ខែធ្នូ ឆ្នាំ ២០២២ ( ឆ្នាំទី៧ )

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន("គម្រោង")គឺជាគម្រោងដែលពិនិត្យជាប្រព័ន្ធនូវលទ្ធភាពរបស់ពលរដ្ឋកម្ពុជាក្នុងការអនុវត្តសិទ្ធិសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ។ ព័ត៌មាននេះបង្ហាញពីចំណុចគន្លឹះទាក់ទងនឹងសេរីភាពខាងការជួបប្រជុំដែលបានមកពីរបាយការណ៍ប្រចាំឆ្នាំទី៧ នៃការឃ្លាំមើលសេរីភាពមូលដ្ឋាន។ នៅក្នុងឆ្នាំ២០២២ គម្រោងបានកត់ត្រាការរឹតត្បិតសេរីភាពខាងការជួបប្រជុំចំនួន ១៦៩ ក្នុងនោះចំនួន ១៣១ (៧៨%) ជាហេតុការណ៍រឹតត្បិតដែលមិនទទួលបានការអនុញ្ញាតតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ដូច្នេះករណីទាំងនេះចាត់ជាការរំលោភបំពាន។ រាជធានីភ្នំពេញមានហេតុការណ៍ចំនួន៨៨% (១៤៩)។

*ផែនទីភូមិសាស្ត្រនៃហេតុការណ៍ដែលពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភបំពានសិទ្ធិសេរីភាពខាងការជួបប្រជុំ*




## ការជួបប្រជុំភាគច្រើនបានធ្វើឡើងដើម្បីតស៊ូមតិ សិទ្ធិដីធ្លី និងសិទ្ធិការងារ




*ការជួបប្រជុំចំនួន១០២ ហេតុការណ៍បានកើតឡើងនៅក្នុងឆ្នាំ២០២២ ដែលធ្លាក់ចុះប្រៀបធៀបនឹងឆ្នាំ២០២១ ដែលមានការជួបប្រជុំចំនួន១៦៥ លើក។ ហេតុការណ៍ភាគច្រើនទាក់ទងនឹងកូដកម្មរបស់បុគ្គលិកក្រុមហ៊ុនណាហ្គាវើលដ៍ ការជួបប្រជុំដែលធ្វើឡើងដោយស្ត្រីថ្ងៃសុក្រ និងព្រឹត្តិការណ៍ជួបជុំរបស់សកម្មជនបរិស្ថាន ឬក្រុមយុវជន។*

## ទណ្ឌកម្មព្រហ្មទណ្ឌត្រូវបានដាក់លើបុគ្គលដែលអនុវត្តសេរីភាពខាងការជួបប្រជុំ




## ពលរដ្ឋបានរាយការណ៍ថាមានសេរីភាពជាងឆ្នាំមុនៗក្នុងការចូលរួមការជួបជុំដោយសន្តិវិធីក្នុងឆ្នាំ២០២២




## រដ្ឋាភិបាលបន្តជ្រៀតជ្រែក ឬហាមឃាត់ការជួបប្រជុំដោយសន្តិវិធី




## ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល ឬសហជីពមានអារម្មណ៍ថាសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពក្នុងការជួបជុំរបស់ពួកគេជាងអំឡុងពេលជំងឺរាតត្បាត ប៉ុន្តែថ្នាក់ដឹកនាំសហជីព មានអារម្មណ៍ថាមានសេរីភាពតិចជាងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល




## នៅឆ្នាំ២០២២ ៥៩% នៃថ្នាក់ដឹកនាំសហជីព (៣៨ ក្នុងចំណោម ៦៥ បានស្ទង់មតិ) បាននិយាយថាពួកគេមានអារម្មណ៍ថាមិនមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំ ២៧% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល (២២ ក្នុងចំណោម ៨០ បានស្ទង់មតិ)




មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights
សមាគមអាដហុក ADHOC
SOLIDARITY CENTER AFL-CIO

CC BY NC SA

ខែកញ្ញា ឆ្នាំ២០២៣